សារព័ត៌មាន ខ្មែរផុស ស.រ.អា

KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641

មាតិការរឿង **Issue 170 Feb.06th.-19th. 2015** **Free**

១-ដំណើរពីអាមេរិកទៅអាស៊ី (ភាគ៤)..................០២
២-រាត្រីសមោសរ យុវជនគនបក្សសង្គ្រោះជាតិ.........០៣
៣-ជីវិតអ្នកបើកយន្តហោះម្នាក់ត្រូវគេមុត...............០៧
៤-ឱកាសរៀនតម្បាញ.......................................០៩
៥-បទសម្ភាសន៍ជាមួយព្រះអង្គម្ចាស់ស៊ីសុវត្ថិ ធម្មិកោ....១០
៦-តើគណបក្សប្រជាជនកម្ពុជាអាចឡើងផុតពី.........១៦
៧-ស៊ូឱ្យមានមិត្តច្រើនជាជាងបង្កើនសត្រូវ...............២១

**Office:** Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

# ក្លឹបសារព័ត៌មាន"ខ្មែរផុសស.រ.អា."
# KhmerPost USA Press Club

The KhmerPost USA, Lowell's Cambodian language newspaper which circulates up and down the East Coast, held another of its Press Club events today at Lowell Telecommunications Corp. **Continued to Page 06**

ថ្ងៃអង្គារ ទី០៦ ខែកុម្ភៈ ឆ្នាំ២០១៥
ផ្សាយដោយ : ឌីក ហាវ
February 6, 2015 - by Richard Howe Jr.



Richard Howe Jr.

កាសែតខ្មែរផុស ស.រ.អា.ផ្សាយចុះឡើងនៅឆ្នេរខាងកើត ជាភាសានៅឡូវែល ខ្មែរនៅឡូវែលបាន ប្រារព្ធព្រឹត្តិការណ៍ "ប្រេសក្លឹប"របស់ខ្លួនថ្មីមួយទៀត នាថ្ងៃនេះនៅ **តទៅទំព័រទី ០៦**



បន្ទប់ធ្វើ"ប្រេសក្លឹបនៅ"LTC



សុបិន ពិន

## លោកគ្រូពេទ្យ ឆាន ទូច ត្រឡប់ទៅរកប្រភពដើម

**ដោយ : ខ្មែរផុសស.រ.អា.**

**ឡូវែល** : តាមការអញ្ជើញរបស់អង្គការសហប្រជាជាតិ ដើម្បីឱ្យមានការជួបជុំគ្នារំលឹកដល់អតីតជុំរំជនភៀសខ្លួនខ្មែរ "ខាវអ៊ីដង" ដែលឥឡូវនៅសល់តែវាលរហោដ្ឋានតែប៉ុណ្ណោះ លោកគ្រូពេទ្យ ឆាន ទូច នៃមន្ទីរពេទ្យ"មេត្តា" នៅឡូវែល បានចេញដំណើរទៅកាន់អតីតជុំរំភៀសខ្លួនខាងខ្មែរឈ្មោះ "ណងចាន់"កាលពីថ្ងៃទី១០ខែមករា២០១៥ នាំទាំងអភិបាលក្រុងឡូវែល អេលីយ៉ុត លោកស្រី រីតា មើស៊ីយើ សមាជិកក្រុមប្រឹក្សាក្រុងនឹងអតីតអ្នកធ្លាប់ឆ្លងកាត់ជុំរំនោះ កាលពី៣០ឆ្នាំមុនជាច្រើននាក់ទៀត ទៅចូលរួមដំណើរផងដែរ មុននឹងបន្តដំណើរទៅកាន់អតីតជុំរំ"ខាវអ៊ីដង"ខាងប្រទេសថៃថែមទៀត។ លោក ឆាន ទូច ធ្លាប់ជាបំរើការជាបុគ្គលិកសុខាភិបាលនៃជុំរំ"សាយធូ" នៅពេលបានមកសហរដ្ឋអាមេរិក ក៏ទៅរៀនតទៅមុខខាងវិជ្ជាពេទ្យ ។ លោកកំពុងរៀនបញ្ចប់ថ្នាក់បណ្ឌិតក្នុងឆ្នាំនេះ ហើយក្នុងពេលជាមួយគ្នានោះដែរ ក៏ជាបុគ្គលិកខ្មែរបំរើការឱ្យពេទ្យមេត្តាតាំងពីកំណើតរបស់ពេទ្យមេត្តានេះដែរ។ **(សូមរង់អានព័ត៌មានពិស្តារនៅលេខក្រោយ)**

## រាត្រីសមោសរសម្លៀកបំពាក់រៀបការអាស៊ី

**ខ្មែរផុសស.រ.អា.**

មនុស្សប្រមាណជាង២០០នាក់ បានមកចូលរួមនឹងទស្សនាការបង្ហាញសម្លៀកបំពាក់វប្បធម៌ នឹងពិធីមង្គលការនៃសហគមន៍វប្បធម៌អាស៊ី រៀបចំឡើងដោយអ្នកស្រីចំប៉ាប៉ាងនឹងមិត្តភ័ក្រ្ត ៤នាក់ទៀតរបស់ខ្លួន កាលពីថ្ងៃសៅរ៍ ទី៧ កុម្ភៈ ឆ្នាំ២០១៥ នៅភោជនីយដ្ឋាន "ប៉ៃលិន" នាទីក្រុងឡូវែល។ គេសង្កេតឃើញមានភ្ញៀវភាគច្រើនជាខ្មែរវ័យក្មេង មានកូរ៉េ មានវៀតណាម មានឡាវ មានថៃ មានឥណ្ឌា មាន ចិន មានខ្មែរ នឹងអាមេរិកាំងផង...។ នាពេលជាមួយគ្នានោះមានពាណិជ្ជករជាច្រើនក្រុម ក៏មកដាក់តុតាំងពិពណ៌ផលិតផលរបស់ខ្លួន មានតាំងពីអ្នកលក់ម្ហូបអាហារ (Delight Bakery) អ្នកលក់ "Newyork life អ៊ិនស្វ៊ិន" មានផលិតផល Herbalife មានអ្នកលក់ផលិតផលធ្វើឱ្យដុសសក់ឡើងវិញ Atom ។ល។

នេះជាលើកដំបូងបង្អស់ដែលនៅក្នុងសហគមន៍ខ្មែរ-អាមេរិកាំងនៅឡូវែលមានការចាប់អារម្មណ៍ទៅលើវប្បធម៌នៃពិធីមង្គលការដែលនៅក្នុងនោះ សំលៀកបំពាក់គ្រឿង គឺជាអលង្ការដ៏សំខាន់បំផុតសម្រាប់លំអររូបរាងកាយស្ត្រីបុរសឱ្យមានរូបរាងស្រស់សង្ហារ **តទៅទំព័រទី០៩**






លោក ឆាន ទូច និងលោក អេលីយ៉ុត នៅព្រំដែនខ្មែរថៃ



សិល្បៈករសម្ដែងការស្លៀកពាក់គ្រឿងការអាស៊ី

Issue 170 Feb.06th.-19th. 2015


# ដំណើរពីអាមេរិកទៅអាស៊ី (ភាគ៦)

តពីលេខមុន

ដោយ : ពិន សំខុន

ក្រុងសៀមរាបស្រោចស្របដោយរុក្ខជាតិធំៗចាស់ឆ្នាំ ថែរក្សាបានល្អ រួមទាំងសួនច្បារលំអ អាគារថ្មីចាស់និងផ្លូវថ្នល់ចាក់កៅស៊ូគ្រប់កន្លែង ត្រៀមសម្រាប់ទទួលភ្ញៀវទេសចរបរទេសក្នុងចំនួនដែលក្នុងរយពេលតែប្រមានជា២០ឆ្នាំប៉ុណ្ណោះ





ខ្ញុំធ្វើយ៉ាងនេះដូចរូបអប្សរា ឬទេ?

ឡើង១០-២០ដងលើសពេលមុនដែលស្គាល់ពីគ្រប់ទិសទីទស្សនាអច្ឆារិយៈវត្ថុមិនដែលមាននៅទីផ្សេងក្នុងពិភពលោក ។ ហេតុអ្វី ?

នេះជាគម្រោងនៃប្រទេសអាស៊ានទាំង១០ ដែលសម្រេចបង្កើតផ្លូវទេសចរមួយរួមគ្នាផ្តួចផ្តើមឡើងដោយប្រទេសថៃដែលជាប្រទេសទេសចរធំជាងគេតែនៅពេលឆ្នាំ១៩៩០-៩១នោះ ទេសចរប្រមាណ១០លាននាក់ក្នុងមួយឆ្នាំៗបានធ្លាក់ចុះរហូតមកនៅប្រមាណពាក់កណ្តាល ក៏ប្រញាប់ប្រញាល់ជម្រុញឱ្យមានផ្លូវនេះឡើងក្នុងគំនិតទាក់ទាញភ្ញៀវបន្ថែមពីប្រទេសដែលមានរមនីយដ្ឋានថ្មីដែលមិនទាន់ប្រើប្រាស់ឱ្យចូលជាចំណើសម្រាប់ទេសចរនៅឡើយ។ ផ្លូវទេសចរនេះក៏បានកើតឡើងនាឆ្នាំ១៩៩៥ គឺជាដំណើរក្នុង "ផែនទីរង្វង់មូល" មួយដែលផ្តើមពី រ៉ងគូននៃប្រទេសភូមាទៅបាងកកនៃប្រទេសថៃទៅសៀមរាបនៃប្រទេសកម្ពុជាទៅវៀងចន្ទនៃប្រទេសឡាវទៅហាណូយណាប្រទេសវៀតណាមទៅបេយ៉ីងនៃប្រទេសចិនទៅ ទីបេត៍នៃប្រទេសចិន ចុងបញ្ចប់ត្រឡប់ទៅរ៉ងគូនវិញ ។ គេពន្យល់ថា ទេសចរមកពីយូរ៉ុបមកពីអាមេរិក ឬមកពីអាស៊ីដូចគ្នាដែលមកចូលទស្សនាក្នុងប្រទេសណាមួយនៃរង្វង់កងចក្រអាស៊ាននេះ អាចទៅទស្សនារមនីយដ្ឋាននៃប្រទេសដទៃឯទៀតក្នុងតម្លៃដំណើរនឹងស្នាក់អាស្រ័យយ៉ាងទាប ហើយអាចបានស្គាល់រមនីយដ្ឋានច្រើនកន្លែងបានទៀតផង ។ ចំណែកឯកម្ពុជាវិញគេបានជ្រើសយកក្រុងសៀមរាប ពីព្រោះទីនោះជារមនីយដ្ឋានពិតប្រាកដអាចទាក់ទាញភ្ញៀវបរទេសបាន បើយន្តហោះចុះនៅទីនោះ ទើបធ្វើឱ្យតម្លៃដំណើរធ្លាក់ចុះមកបានតែបើគេយកភ្នំពេញជាចំណុចនៃកងចក្រទៅវិញ ទេសចរនឹងចំណាយលុយនឹងពេលវេលាច្រើនសម្រាប់ទៅមកពីភ្នំពេញ-សៀមរាប ដែលជាកត្តាតម្លៃរារាំងមិនឱ្យអាស៊ានយកចំណុចភ្នំពេញចូលក្នុងកងចក្រទេសចរអាស៊ាននេះបានទេ។ ហេតុនេះហើយបានជាការឃោសនានៃប្រទេសទាំង១០នៃអាស៊ាននេះ បាននាំឱ្យមានការកើនទេសចរនៅសៀមរាបនឹងនៅកម្ពុជាយ៉ាងច្រើន គួរឱ្យកត់សំគាល់បាន -ចំណែកឯបាងកកខ្លួនឯងក៏បានកើនចំនួនទេសចរឡើងវិញ ដោយសារនយោបាយរកស៊ីរួមគ្នាក្នុងសហគមន៍អាស៊ាននេះ។

មកដល់សៀមរាបភ្លាមខ្ញុំនឹកទៅរកគ្រួសារបងប្អូនជីដូនមួយ គឺបងហៃចាស់វស្សាក្រុងសៀមរាបចូលនិវត្តនិនៅទីនោះ យើងរីករាយនឹងបានជួបគ្នាឡើងវិញ បន្ទាប់ពីបែកខានឃើញគ្នាប្រមាណ១៣-១៤ឆ្នាំចុងក្រោយនេះ ។ គាត់នៅតែរួសរាយនិយាយកំប្លែងលេងសើចដូចកាលពីក្មេងដដែល ។ គាត់ចេញពីភ្នំពេញ មកតាំងទីរកស៊ីខាងដឹកជញ្ជូនភ្ញៀវទេសចរ នាអំឡុងឆ្នាំ១៩៩០ បានកាក់កប

តទៅទំព័រទី ០៤


# ការិយាល័យច្បាប់ ហ្វ្រង់ស៊ីស្កូ ជេ.រូសា



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រូសា



Andrew 'Bunna' Taing, Esq.
មេធាវី ប៊ុណ្ណា អែនឌ្រូ តាំង

Law Office of:
FRANCISCO J. ROSA
ATTORNEY AT LAW

| SERVICES | តំណាងក្តីដូចខាងក្រោម |
|---|---|
| Auto Accidents/ Personal Injury | គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ |
| Bankruptcy | ក្ស័យធន |
| Immigration | អន្តោប្រវេសន៍ |
| Consumer Protection | ការពារអតិថិជន |
| Real Estate Closings/Disputes | ទំនាស់ផ្ទះអចលនវត្ថុ |
| Divorces Child Custody | លែងលះ និងអាណាព្យាបាលកិច្ច |

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | help@attorneyrosa.com
www.attorneyrosa.com



# ខូម័រ សិប្បកម្មឆ្នៃរូបសំណាកក្រានីត
COLMER MONUMENT WORKS

Memorials of Distinction
អាស័យដ្ឋាន:1025 Lawrence Street Lowell, MA 01852-4898
**(978) 452-7821**



- Granite Memorials — ផ្នូររាងបញ្ឈរធ្វើពីថ្មក្រានីត
- Granite & Bronze Markers — ផ្នូរផ្តេកមានឆ្លាក់សរិទ្ធលេថ្មក្រានីត
- Cemetery Lettering in Khmer — មានឆ្លាក់អក្សរខ្មែរលើថ្មនៃផ្នូរ

COLMER Monument Works

ភាពថ្លៃថ្នូរ កិត្តិយស និងការគោរពជូនលោកអ្នក
Honor. Dignity. Respect for All

# រាត្រីសមោសរ យុវជនគណបក្សសង្គ្រោះជាតិនៅឡុងប៊ិចទទួលទ្រង់ ស៊ីសុវត្ថិ ធម្មិកោ

**កខ្មែរផុសស.រ.អា.**

ធាតុអាកាសត្រជាក់ក្រោមសូន្យនៃរាត្រីទី២៤មករា២០១៥ ព្យុះព្រិលធ្លាក់តាំងពីព្រលឹមរហូតដល់ព្រលប់ទ្រង់ធម្មិកោជាសមាជិកគណកម្មការដឹកនាំគណបក្សសង្គ្រោះជាតិនៅតែទទួលភ្ញៀវជាង២០០នាក់មកស្វាគមន៍ទ្រង់ប្រកបដោយភាពរីករាយនឹងសាមញ្ញជាងសព្វមួយដងនៅ "អាគារសំពៅមាសក្រុងឡូវែល"-ភាពធម្មតានៃការបោះបង់រាត្រីសមោសដោយសារធាតុអាកាសមិនល្អបានត្រូវផ្លាស់ប្តូរដោយសារវត្តមានរបស់ទ្រង់ស៊ីសុវត្ថិ ធម្មិកោ ។ លោក ស៊ិនួន ខាំ



ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ធម្មិកោ



សមាជិកសំខាន់ៗគណបក្សសង្គ្រោះជាតិ



យុវជនច្រៀងចម្រៀងស្នេហាជាតិ



ពិធីករ សូបិន និងវណ្ណៈ ថតជាមួយព្រះអង្គម្ចាស់

ប្រធានគណបក្សសង្គ្រោះជាតិរដ្ឋម៉ាសាឈូសិតនិយាយថា "មានភ្ញៀវថ្មីៗមកច្រើនដែលមិនមែនជាសមាជិកគណបក្សមកចូលរួមដែរ"ខុសពីសព្វមួយដងលក្ខណជាកិច្ចប្រជុំតានតឹងនយោបាយបានថយមកនៅជាលក្ខណផ្តល់ព័តិមានស្នេហាជាតិនឹងរីករាយដោយបានជួបថ្នាក់ដឹកនាំថ្មីទៅវិញ។ ចំណុចខ្លាំងមួយចំនួននៃការរៀបចំរាត្រីសមោសក្រោមការទទួលខុសត្រូវនៃក្រុមយុវជនសង្គ្រោះជាតិដឹកនាំដោយលោក ប៉ែន សុខ ផល គឺបន្ថែមដោយវត្តមានរបស់លោក រ៉តនី អេលីយ៉ុត អភិបាលក្រុងនឹងមកនិយាយអំពីទស្សនកិច្ចរបស់លោកទៅកម្ពុជាដែលជាការរង់ចាំរបស់សហគមន៍ខ្មែរនឹងវត្តមានលោកតំណាងរដ្ឋខ្មែរថ្មី រ៉ាឌី ម៉ម ដែលបានត្រូវលោកអតីតតំណាងរាស្ត្រខ្មែរ សាង សាន ប្រកាសយកជាសាក្សីនៃការធ្វើបាបពលរដ្ឋខ្មែរថា "ថ្មីៗនេះបានសម្រក់ទឹកភ្នែកជូនសកម្មជនរងគ្រោះនៅមុខគុកព្រៃសរ"បណ្តាលឱ្យបរិយាកាសចង្អៀតចង្អល់ដោយការចោទប្រកាន់ថា បានក្បត់គ្នាបានរំសាយចេញគួរឱ្យកត់សំគាល់។

លោក រ៉តនីយ អេលីយ៉ុត និយាយថា "លោកបានទៅកម្ពុជានាំការផ្តាំផ្ញើររបស់ពលរដ្ឋក្រុងឡូវែលទៅជូនរដ្ឋាភិបាលខ្មែរលោកបានទៅដល់ទល់ដែនខ្មែរ-ថៃ ទៅទស្សនាអង្គរវត្តទៅទស្សនាភ្នំពេញនៅប្រទេសដ៏ល្អនឹងរាក់ទាក់របស់លោកអ្នកទៅជួបលោក សម រង្ស៊ី លោក កឹម សុខា លោកស្រី មូរ សុខហួរ ជាថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិខ្ញុំបាននាំពាក្យទៅដល់អ្នកទទួលខុសត្រូវរួចហើយ ថែមទាំងបានទៅឃើញអ្នកជាប់ទោសនៅពន្ធនាគារទៀត តាមការប្រឹងប្រែងរបស់គណបក្សប្រឆាំងតែពេលខ្ញុំរៀបចេញដំណើរមកឡូវែលវិញ លិខិតផ្លូវការមួយមកដល់សំដែងការសោកស្តាយពីការដែលខ្ញុំទៅជួបអ្នកជាប់ទោសដែលរដ្ឋាភិបាលមិនបានអនុញ្ញាត្តិ" -តែលោក រ៉តនីយ ពុំបានរំលឹកពីការចុះហត្ថលេខារបស់លោកជាមួយអភិបាលក្រុងភ្នំពេញទេ។

ព្រះអង្គម្ចាស់ ធម្មិកោ ជាភ្ញៀវកិត្តិយសរបស់យុវជនសង្គ្រោះជាតិបាននិយាយថា"១-ទទួលស្គាល់ថា មានថ្ងៃ៧មករាជាថ្ងៃជ័យជំនះលើខ្មែរក្រហមមែន រីឯក្រុមសមមិត្រ ហ៊ុន សែន ជាខ្មែរក្រហម"២ធ្នូ១៩៧៨" កើតបាន ២អាទិត្យ មិនអាចវាយឈ្នះខ្មែរក្រហម ប៉ុល ពត នៅថ្ងៃ"៧មករា១៩៧៩"បានទេ គឺទ័ពយួនទេ ជាអ្នកចូលមកវាយលុក ២-គណបក្សហ៊្វុនស៊ិនប៉ិចដែលមានខ្ញុំជាប្រធានដំបូងបង្កស់នាឆ្នាំ ១៩៨១ តាមមាគ៌ានៃសម្តេចនរោត្តម សីហនុ គឺបណ្តេញយួនចេញពីកម្ពុជា...មកទល់ថ្ងៃនេះ តើប្រទេសខ្មែរមានឯករាជ្យនឹងអធិបតេយ្យហើយឬនៅ? ថាទេ! ដូច្នេះជាមួយពលរដ្ឋខ្មែរជាមួយសង្គ្រោះជាតិយើងនៅតែបន្តរការតស៊ូរបស់យើងរំដោះជាតិចេញពីវៀតណាមមកវិញតទៅទៀត ដោយប្រើច្បាប់ ៣-កិច្ចព្រមព្រាងរវាងគណបក្សប្រជាជននឹងសង្គ្រោះជាតិនឹងសម្រេចផ្តល់ឱ្យសភាជាតិធ្វើវិសោធនកម្មលើច្បាប់បោះឆ្នោតនឹងគណកម្មការជាតិរៀបចំការបោះឆ្នោតនៅខែកុម្ភៈនេះហើយ ៤-ការបោះឆ្នោតកន្លងមកសម្លេងឆ្នោតគណបក្សប្រជាជនមានតែ៣០-៣៥ភាគរយដែលដំណាងឱ្យសម្លេងជាង៣លាននាក់តែប៉ុណ្ណោះ ប្រសិនបើគ្មានការលួចបន្លំតាមការប្រើអំណាចរដ្ឋាភិបាលនឹងគ.ជ.ប. ទេ មិនអាចយកឈ្នះបានទេ ពីព្រោះនៅសល់ប្រជាពលរដ្ឋជាង៦-៧លាននាក់ទៀតឯណោះដែលមិនព្រមបោះឆ្នោតឱ្យគណបក្សប្រជាជនជារៀងរហូតមកនោះទេ"។

ចំណុចខ្លាំងផ្សេងទៀតនោះ សូបិន ពិន ជានាយកគ្រប់គ្រងខ្មែរផុសស.រ.អា បានទទួលកិត្តិយសឱ្យធ្វើជាពិធីករដឹកនាំកម្មវិធី-បង្ហាញភ្ញៀវកិត្តិយស រួមទាំងក្រុមសិល្បៈសម័យ នឹងបុរាណដោយនាថការីសមាគម"អង្គរ" ជាដៃគូរជាមួយ វណ្ណ ម៉ែន នារាត្រីនោះ- ហើយព្រះអង្គម្ចាស់ធម្មិកោក៏បានចងដៃចម្រៀងរបស់ "ដឺប៊ីធើល" បីបទ ជាមួយក្រុមតន្ត្រី"ខេមរៈ" ជូនដល់ភ្ញៀវរាត្រីសមោសរដែលភ្ញាក់ផ្អើលយ៉ាងខ្លាំងមិននឹកស្មានថាស្តេចអង្គនេះ មានទេពកោសល្យផ្សេងមួយទៀត ក្រៅពីនយោបាយខ្ពស់យ៉ាងនេះសោះ ។ ម៉ោង១២អាធ្រាតហើយ ភ្លេងបានបន្លឺបទ"សាយូណារ៉ា" ធ្វើឱ្យភ្ញៀវលាគ្នាទាំងបង្ខំចិត្ត ៕









តមកពីទំព័រទី ០២

## ដំណើរពីអាមេរិកទៅអាស៊ី...

គ្រាន់បើរស់តាមសម្មាជីវោ រហូតដល់គ្រប់គ្រងរថយន្តដឹកភ្ញៀវប្រមាណ១០គ្រឿង ទិញបានដីសង់ផ្ទះ សង់កូនភូមិគ្រឹះ នឹងទិញផ្ទះល្វែងបាន ៣-៤នៃឆ្នាំ២០០០ ជាសម្បត្តិថ្លៃថ្នូរដែលគណបក្សប្រជាជនគេឱ្យរស់ជាសហគមន៍ចាស់របស់គេ ។ ជាអកុសលគាត់បានផ្ទុងប្តើមកូនធំ១២-៣ ឱ្យមានគ្រួសារសមប្រកបចែកកើ្តឱ្យបើកហាងរកស៊ីឱ្យឡានដឹកភ្ញៀវទន្ទឹមគ្នាតែការរកស៊ីរបស់កូនមិនបានចំរើនទេ ក៏លក់សងបំណុលជំនួសកូនម្តងបន្តិចរហូតដល់ត្រឡប់មករស់នៅផ្ទះនៅជាយក្រុងដាច់ស្រយាល ស៊ីប្រាក់"រ៉ឺត្រែត" ជាមួយប្រពន្ធគាត់ជាយាយតាយ៉ាងស្ងាត់ស្ងៀម ។ គ្រួសារខ្ញុំបែកជាធំឡើងវិញហើយ តែនៅរាប់រកស្គាល់គ្នាតិចណាស់ ហេតុនេះហើយបានជាសូបិនដែលមានវប្បធម៌ដំណរកូនកាត់ចិនយល់ថា នាំ ប៉ុណ្ណារ៉ូ ឱ្យផ្តើមស្គាល់ក្រុមគ្រួសារខាងប្តីឡើងវិញ ដល់ធំឡើងអាចនឹងនៅចាំបងប្អូនមាមីងបានខ្លះ សំរាប់ជីវិតអនាគតរបស់គេ... នឹកឃើញដល់គំនិតនេះធ្វើឱ្យខ្ញុំរភើបក្នុងចិត្តសរសើដល់បុព្វបុរសចេះរកប្រដៅកូនចៅឱ្យស្រឡាញ់ ហើយថែរក្សាពូជ ឬ"សែ"របស់ខ្លួន ។ ខ្ញុំបានជួបបង ហៃ បងហាក់ជាប្រពន្ធរបស់គាត់ តែមិនបានជួបក្មួយៗជាកូនរបស់គាត់ដែលនៅសៀមរាបដែរនោះ ពីព្រោះពេលស្នាក់អាស្រ័យមានតិចពេក ។

ពេលស្នាក់អាស្រ័យតិច ពីព្រោះចង់យកពេល ឱ្យច្រើនបន្តិចសម្រាប់"ចំការវប្បធម៌ខ្មែរ" ដ៏ធំធេងមួយ គឺអង្គរវត្តដែលជាគោលដៅរបស់សូបិន និង ប៉ុណ្ណារ៉ូ ដែលនឹងមានភ័ព្វសំណាងទៅជាន់ដីទីនោះជាលើកទី១ នៅព្រឹកស្អែកនេះហើយ ។

ស្នាក់អាស្រ័យនៅដំណាក់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ ហៅ "តូមីកូ"ឬ"តូមី" ជាមិត្តភ័ក្រ្តចាស់អាយុប្រហាក់ប្រហែលគ្នា តែប្អូនខ្ញុំបន្តិចបានអ្នកម្នាងក្មេងដូចគ្នា កូននៅតូចដូចគ្នានិយាយចុះសម្រុងគ្នាណាស់ ។ នៅទីនោះ គឺជា "ជង្រុកវប្បធម៌"ដ៏សំខាន់មួយទៀត នាំបទពិសោធន៍ជារាជវង្សជាប់ពីតំណរអម្បូរអ្នកសង់អង្គរវត្ត



ហើយធ្លាប់រស់នៅក្បែរព្រះមហាក្សត្រមុន នឹងកំពុងចេញចូលជាទីប្រឹក្សាព្រះមហាក្សត្រសព្វថ្ងៃ អ្នកទាំងពីរជាគ្រួសារស្រឡាញ់សិល្បដ៏ជ្រាលជ្រៅដូចគ្នាសំណាក់នៅទីនោះ គឺជាសំណាងរបស់យើងជាភ្ញៀវព្រះអង្គណាស់ ។

ស្អែកឡើងម៉ោង៩ព្រឹក រ៉ឺម៉កម្ហូតូដែលយើងកក់ទុកសម្រាប់មួយថ្ងៃពេញបានមករង់ចាំយើង រួចជាស្រេចយើងនាំគ្នាទៅហូបគុយទាវនៅក្បែរដំណាក់មិនឆ្ងាយប៉ុន្មានពីសារមន្ទីរជាតិជាមួយគ្រួសារយើងទាំងពីរ នាទៀមតូចច្រឡឹងមួយតែភ្ញៀវច្រើនតាំងពីព្រលឹមមកម្លេះនៅក្បែរនោះមានហាងមួយទៀតដែលគេដាក់ប៉ាយគេថា "អាយូន"ធ្វើឱ្យយើងអស់សំណើចពេលកាត់ទីនៅម្តងៗ ។ ទៀមនោះស្អាត មានអនាម័យ គ្រាន់បើទាំងគុយទាវទាំងកាហ្វេក៏ឆ្ងាញ់ធ្វើម្ហូបនឹងបំរើភ្ញៀវដោយម្ចាស់ផ្ទះតែម្តងតាមទម្លាប់នៃការរកស៊ីតាំងពី១០-២០ឆ្នាំមុនមក ដែលខុសប្លែកពីហាងឯទៀតៗ ដែលបានក្លាយជាធំជារបៀបរបបសម័យមានអ្នកបំរើស្លៀកពាក់ឯកសណ្ឋានស្ថិតនៅក្បែរប្រជុំជននៃហាងជញ្ជាំងកញ្ចក់អស់ទៅហើយ ។ ថ្មើរនេះទៅហើយភ្ញៀវអង្គុយក្បែរយើងអ្នកមកហូបគុយទាវបានស្បៀយនៅសល់តែភ្ញៀវមកផឹកតែឬកាហ្វេមួយពែងជជែកគ្នាលេងពីការរកស៊ីព័ត៌មានប្រចាំថ្ងៃតាមតែរូបភាពតាមទូទស្សន៍បញ្ចាំងមកតែប៉ុណ្ណោះ។ យើងចេញពីទៀមគុយទាវខ្ញុំដកអារម្មណ៍ពីកម្ពុជា នា-ពេលព្រលឹមជំនាន់ដើម ឯសូបិននឹកទៅដល់ស្រុកបាយឆៅរបស់គេនៅកម្ពុជាក្រោមដែលមិនខុសនេះប៉ុន្មានទេ គ្រួសារយើងក៏បែកគ្នាត្រឹមនេះដោយនឹកថា ពេលណាមួយម្ចាស់"តូមី" នឹងអ្នកម្នាង"ម៉ាច"នឹងចូលរួមដំណើរទស្សនាអង្គរជាមួយយើងជាមិនខាន។

ព្រឹកនេះយើងមានគម្រោងទៅទស្សនាប្រាសាទ"អង្គរតូច" **តទៅទំព័រទី ០៥**

ចាប់ផ្តើមទទួលពាក្យសិស្សសុំចូលរៀនពីពេលនេះតទៅ
ពីថ្នាក់មត្តេយ្យកិរិតទាប K1ដល់ ទី៧! *កន្លែងថ្នាក់រៀនមានកំណត់*

***ថ្នាក់ត្តេយ្យសិក្សាកិរិតទាបថ្មីសំរាប់សិស្សអាយុ៤ឆ្នាំ!***

LCCPS
LOWELL COMMUNITY CHARTER PUBLIC SCHOOL

សេចក្តីជូនដំណឹង
Information Session
Wednesday, February 11th @5:30 PM
Register Now!



សាលារៀនឆាទ័រផ្តល់ជូន:
- បន្ថែមថ្ងៃ និងឆ្នាំសិក្សា
- មិនបង់ថ្លៃសិក្សា - *យើងជាសាលារៀនរដ្ឋ!*
- កម្មវិធីផ្តល់រង្វាន់សិស្សរៀនពូកែ
- កម្មវិធីបន្ថែមពេលសិក្សា
- កម្មវិធីគាំទ្រសំរាប់ភាសាអង់គ្លេស និងតម្រូវការពិសេស

សាលារៀនសាធារណៈ
សហគមន៍ឆាទ័រ
នៃទីក្រុងឡូវែល
បានចំណាត់ថ្នាក់
លេខ១រយៈពេល
បីឆ្នាំជាប់គ្នាកន្លងមក!

សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងមក Deborah Ye Motew អ៊ីមែល dmotew@lccps.org
ឬទូរស័ព្ទលេខ ៩៧៨-៣២៣-០៨០០

ភាពជោគជ័យ ភាពដឹកនាំ ឧត្តមភាព

Lowell Community Charter Public School • 206 Jackson Street • Lowell, MA 01852 • 978-323-0800 • www.lccps.org

តមកពីទំព័រទី ០៤

## ដំណើរពីអាមេរិកទៅអាស៊ី...

ពេញមួយថ្ងៃបន្ទាប់មកសឹមទៅមើលប្រាសាទអង្គរធំ ឬបាយ័ននៅថ្ងៃស្អែកទៀត ។ យើងយកមគ្គុទេសម្នាក់ដើម្បីជួយពន្យល់ពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលចាំជូនដំណើរនៅអង្គររួចហើយដែរ ។ នៅតាមផ្លូវដែលរីកធំៗគ្រប់កន្លែងគេហដ្ឋាន



ហាងថ្មីៗ សណ្ឋាគារធំៗ នឹងអាគាររដ្ឋបាល សាលាខេត្តរៀបចំទទួលភ្ញៀវនឹងទេសចរបានប្រសើរខុសពីពេលមុនៗច្រើនណាស់ តែសំណង់ថ្មីៗទាំងនោះបានបញ្ចប់នៅត្រឹមទ្វារចូលអង្គរ ដែលស្ថិតនៅប្រមាណជាពាគីឡូម៉ែត្រ ពីរមនីយដ្ឋាន គឺនៅចន្លោះនោះហើយ ដែលយើងផ្ដើមចូលក្នុងព្រៃស្រោងអន្ទង់អន្លោច ឮសូរតែរៃយំ រហូតដល់ប្រាសាទអង្គរវត្តលេចឡើងឆ្លោរពីមុខយើង... ផ្ទាំងទេសភាពនៃប្រាង្គប្រាសាទទាំងមូលបានបង្ហាញពីភាពអស្ចារ្យ សម្បើម អច្ឆារិយៈ គឺសំណង់សតវត្សទី៩ មានកំពូលស្រួច៥ ដ៏ធំព័ទ្ធដោយថែវ៤ជ្រុងស្មើរ បង្កើតជាបរិវេណការពារប្រសាទកណ្ដាលរបស់ខ្លួននៅពីក្រៅថែវនោះប្រឡាយទឹកព្រែកជីកស្មើរធេងប្រវែងប្រហែល ១០០ម៉ែត្រទទឹងព័ទ្ធជុំជិតការពារពីក្រៅថែវនោះថែមទៀត មានតែច្រកតែមួយគត់ដែលគេអាចចេញចូលបាននៅពីខាងមុខប្រាសាទបែរទៅរកទិសថ្ងៃលិចតាមផ្លូវថ្មយ៉ាងវែងប្រមាណ៥០០ម៉ែត្ររចនាជាស្ពាននាគរាជអមដោយប្រាសាទបណ្ណាល័យតូចៗ នៅសងខាងស្ពាននោះ ទើបអាចចូលដល់ក្នុងបរិវេណប្រាសាទបាន ។ មិនបាច់ពន្យល់អ្វីទាំងអស់ក៏គេអាចយល់បានថា សំណង់នេះ ជាកំពូលស្នាដៃស្ដេចនៃប្រទេសដ៏មានស្មេរភាពមាំមួនមួយអង្គមានចំណេះនឹងជំនឿសាសនាដ៏ជ្រាលជ្រៅនឹងជាអ្នកចម្បាំងដ៏ពូកែរថែមទៀត ទើបអាចសង់ប្រាសាទរបៀបនេះបាន នឹកមកសម័យនេះភ្លាមពុំមានមេដឹកនាំណាមួយអាចមានលក្ខណៈសម្បត្តិប្រៀបប្រដូចទៅជំនាន់នោះនៅឡើយទេ សូម្បីតែអាមេរិកាំងដែលបញ្ជូនអ្នកអវកាសទៅដល់ឋានព្រះអង្គារទៅហើយក្ដីក៏ស្មើតែប្រៀបធៀបទៅស្ដេចខ្មែរពីជាង១ពាន់ឆ្នាំមុនមិនបានផង ។



យើងដើរចូលទៅក្នុងប្រាសាទ "អង្គរតូច" ប្រកបដោយក្ដីរំភើបចិត្តទាំងអស់គ្នាដោយបានដើរជាន់រម្មណីយដ្ឋាន ដ៏មានមហិទ្ធិរិទ្ធដាមដោយប្រវត្តិសាស្ត្រដែលលាក់អាថិកំបាំងជាច្រើននៅឡើយ តែគេដឹងច្បាស់ថា បុព្វបុរសមានឈាមជ័រជាខ្មែរដូចពួកយើងដែរ បានន័យថា ខ្មែរយើងគឺជាម្ចាស់ពិតប្រាកដនៃសម្បត្តិវប្បធម៌ដ៏សម្បើមនេះ ។ យើងដើរមើលផ្ទាំងចម្លាក់លើជញ្ជាំងថែវពីមួយកន្លែងទៅមួយកន្លែងទៀត ដោយមិននឿយហត់ ទោះជាញើសហូរពេញខ្លួនដោយកំដៅថ្ងៃនៃធាតុអាកាស "ត្រូពិកាល" នៃកម្ពុជា ពេលនោះទើបយើងនឹកទៅដល់ក្រមារដ៏មានប្រយោជន៍ដែលយើងកំពុងបង់ករយកមកជូតមុខបណ្ដើរទឹកស្វើចសរសើរស្នាដៃសំណង់នឹងចម្លាក់បណ្ដើរ ហើយក្រមារក៏ឆាប់ស្ងួតទៅវិញផងទៀត។ ប៉ុណ្ណារ៉ូ ប្រលែងលេងនឹងដុំថ្ម ដោយលោតពីដុំមួយទៅមួយទៀត លេងលាក់ខ្លួនតាមចន្លោះទ្វារជាប់ៗគ្នាមិនចេះខ្ជិល ។ ថ្ងៃនេះយើងមិនអាចឡើងកំពូលកណ្ដាលបានទេ ដោយជាថ្ងៃមានបុណ្យសាសនាមួយឆ្នាំស្រីប្រុសដើរខ្វាត់ខ្វែងចាំយាមរមនីយដ្ឋានមិនឱ្យក្លាយជាទីក្រខ្វក់ នឹងណែនាំភ្ញៀវឱ្យប្រកាន់ការប្រុងប្រយ័ត្នក្រែងមានគ្រោះថ្នាក់។ ថ្មជាច្រើនដែលរលំបាក់ធ្លាក់មកដីពុំទាន់រកកន្លែងដាក់ឱ្យត្រូវកន្លែងដើមរបស់វាបាននៅឡើយ ៕

(នៅមានតទៅភាគពេទៀត)



CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវេយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- រីកខឹខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY
77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

ការិយាល័យ មេធាវី
ថំមាស ស្ពាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្ដីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766

តមកពីទំព័រទី ០១

## ក្លឹបសារព័ត៌មានខ្មែរផុសស.រ.អា

LTC Lowell Telecommunication Corp ។ រ៉ជ័រ ពិន ជាសហនាយកការផ្សាយបានពន្យល់ដោយផ្តើមថា លោកបានបង្កើត"ប្រេសក្លឹប"នេះឡើង តាំងពីឆ្នាំ១៩៩៤នៅពេលដែលលោកកាន់ដំណែងជាប្រធានសមាគមអ្នកសារព័ត៌មានខ្មែរ ។ អត្ថន័យរបស់ព្រឹត្តិការណ៍នេះ គឺណែនាំឱ្យប្រជាពលរដ្ឋជួបគ្នា ដើម្បីបង្កើនទំនាក់ទំនងរវាងគ្នានឹងគ្នាដោះស្រាយបញ្ហាដែលប៉ះពាល់ដល់ពួកគេ ។ រ៉ជ័រ ជាមួយសហនាយកការផ្សាយ សូបិន ពិន ជាភរិយារបស់គាត់បានបន្ត"ប្រេសក្លឹប"នេះនៅឡូវែលប្រកបដោយជោគជ័យទៀតដោយអញ្ជើញភ្ញៀវផ្លូវការមកស្តាប់ការចាប់អារម្មណ៍របស់សមាជិកសហគមន៍ខ្មែរនៅឡូវែល ហើយនឹងឆ្លើយតបទៅនឹងការចាប់អារម្មណ៍ទាំងនោះ ។

Continued from page 01

## Khmer Post usa Press club

Roger Pin, a co-publisher of the paper, explained that he began these Press Clubs back in 1994 when he was the President of the Cambodian Journalists Association. The purpose was and is to bring people together to communicate about issues that affect them. Roger and his co-publisher (and spouse) Soben Pin have been very successful in transplanting Press Club to Lowell by inviting elected officials to attend, to listen to remarks by members of the Lowell Cambodian community, and to respond to thremarks.

កម្មវិធីប្រេសក្លឹបនាថ្ងៃនេះមានពាចំណុច គឺវិស័យអប់រំ ពាណិជ្ជកម្មខ្នាតតូច និងសុវត្ថិភាពនៃផ្ទះ ជួល ។ អ្នកដែលបានចូលរួមមានលោកតំណាងរដ្ឋ ថម ក្កោលដិន លោកអភិបាលក្រុង អេល្យុត រ៉តនីយ សមាជិកក្រុមប្រឹក្សាក្រុង ដង រូក នឹង ខូរី បាលិនជ័រ ។ បានមកចូលរួមដែរមានអតីតក្រុមប្រឹក្សាក្រុង វ៉ាស្នា នួន នាយករងនៃសាលាក្រុង ខេវិន ខហ្វលិន នឹងអនុសេនីយឯកខាងប៉ូលីស ខិលី រីឆឺដសិន ។



Today's Press Club had three topics: education; small business; and safe rental housing. In attendance were State Rep Tom Golden, Mayor Rodney Elliott and City Councilors Dan Rourke and Corey Belanger. Also attending were former City Councilor VesnaNuon, Deputy DPD Director Kevin Coughlin and Lowell Police Captain Kelly Richardson ។

សូបិន ពិន បានផ្តើមប្រធានបទដំបូងរបស់ខ្លួនក្នុងវិស័យអប់រំ ដោយនិយាយថា ៣២ភាគរយ ក្នុងចំណោមសិស្សជាង៣០០០នាក់នៅវិទ្យាល័យឡូវែលជាសិស្សអាស៊ី ហើយនឹងមាន៦៧ភាគរយ ជាសិស្សនៃគ្រួសារដែលមានប្រាក់ចំណូលតិចតួច។ លោក ប៉ន សូ ដែលជាសាស្ត្រាចារ្យ២៧ឆ្នាំ នៅវិទ្យាល័យឡូវែលនោះនិយាយថា "កូនសិស្សខ្មែរត្រូវការជាខ្លាំងឱ្យគេជួយគាំទ្រ" គាត់បន្តថា "ជីវិតក្មេងទាំងនោះបានឆ្លងពីលឿនពេកទៅជាយឺតយ៉ាវជាមួយគ្នានោះគាត់បានឆ្លៀតឱកាសប្រកាសពីបំណងឈរឈ្មោះជាបេក្ខជង នាឱកាសបោះឆ្នោតក្រុមប្រឹក្សាសាលាក្រុងនៅឆ្នាំនេះ ។



លោក ប៉ន សូ

Soben Pin introduced education as the first topic by stating that 32% of the 3000-plus students at Lowell High School and that 67% of all the LHS student come from low-income families. A gentleman named Pan So who has been a teacher at Lowell High for 27 years spoke about the need for more intensive assistance for Cambodian students. He said that the life of young people passes too quickly to delay. He also used today to announce his candidacy for the Lowell City Council in this year's city election.

**ប្រធានបទបន្ទាប់ គឺវិស័យពាណិជ្ជកម្មខ្នាតតូចៈ** វាគ្មិនសំខាន់គឺ លី ម៉ានីផូ ជាម្ចាស់ហាង"Little Delights Bakery"នៅផ្លូវមេរីម៉ាក។ លីបានពន្យល់ថា នាងមកដល់រដ្ឋម៉ាសាឈូសិត តាំងពីនៅក្មេង នាឆ្នាំ១៩៨៤? មករស់"ឃ្វិនចុិ"នៅជាមួយគ្រួសារបន្ទាប់មកនៅ"ប្រុកតុន"នាងកត់បានសំគាល់ថា ក្រុងទាំងនោះមិនមានជនជាតិអាស៊ីរស់នៅទេ តែដល់ពេលចុងបញ្ចប់មកដល់ឡូវែលនៅពេលឃើញជនជាតិអាស៊ីអគ្នេយ៍ដ៏ច្រើនរស់នៅជុំគ្នាកន្លែងតែមួយនេះ គឺជាបទពិសោធន៍ថ្មីមួយដ៏អស្ចារ្យណាស់សម្រាប់នាង ។



អ្នកស្រី លី ម៉ានីផូ

### Lee Many Pho

The next topic was small business. The main speaker was Lee Many Pho, the owner of Little Delights Bakery on Merrimack Street. Lee explained that she came to Massachusetts as a young girl in 1984. Her family settled in Quincy and then Brockton. She mentioned that neither of those cities had many Southeast Asian residents so when she finally made it to Lowell, seeing so many Southeast Asian people in one place was a new and exciting experience for her.

លី ពន្យល់ថា នាងបានរៀនឆ្លងកាត់ផុតមហាវិទ្យាល័យ រហូតទៅចូលផ្នែកសិក្សាថ្មីផ្សេងទៀតនៅពេលដែលនាងចង់បើកហាងតូចមួយអ្នកនៅជុំវិញម្នាក់ៗបានបង្អាក់ទឹកចិត្តនាងដោយនិយាយថា "ប្រសិនបើអ្នកទៅធ្វើការឱ្យអ្នកដ៏ទៃវិញប្រហែលជាស្រួលជាង" ជាម្ចាស់ហាងរបស់ខ្លួនឯងជាការលំបាកមែន តែធ្វើឱ្យនាងរីករាយជាទីបំផុត! នាងបន្តថា "ក្មេងម្នាក់ៗមិនដូចគ្នាទេ សិស្សវិទ្យាល័យ គួរតែថៃគ្នាឱ្យពួកគេធ្វើអ្វីដែលគេចង់នឹងបង្រៀនបច្ចេកទេសតាមតម្លៃនៃក្តីស្រម័យរបស់គេ"។ នាងសង្កត់ពាក្យថា "ចំពោះយុវជនទាំងនោះ យើងគួរតែសាកល្បងខំធ្វើអ្វីកុំឱ្យគេចេញពីឡូវែលដោយនិយាយថា" "ត្រូវតែរក្សាកំណប់របស់យើងនៅទីនេះ" នាងបញ្ចប់ថា "បទបិសោធន៍ទាំងនេះហើយដែលធ្វើឱ្យខ្ញុំចង់ជួយកូនខ្មែរទាំងនោះ ធ្វើជាអ្នកណែនាំ និងជាគំរូរបស់ពួកគេ" ។

Lee explained that she went through college intending to go into an entirely different field and when she decided she wanted to start a small business, everyone around her tried to discourage her, saying it would be much easier to work for someone else. Owning her own business has been hard work but she enjoys it very much. She said every kid is different and high school students shouldn't be nudged into vocational and technical training at the expense of their dreams. She said young people should be encouraged to pursue their dreams, especially if they are entrepreneurial. She emphasized that those are the kids we should be trying to retain in Lowell, saying "let's keep all of our treasures here." She said the entire experience has inspired her to help Cambodian kids as a mentor and role model.

វាគ្មិនបន្តបន្ទាប់ខ្លះបានឆ្លើយតបនឹង លីៈ ខេវិន ខហ្វលីន សួរថា "តើសាលាក្រុងគួរធ្វើអ្វីដើម្បីបង្កើនចរាចរភ្ញៀវអ្នកទិញភ្ជាប់ពីមណ្ឌល "ខិបពលសគ្វែ" ទៅ "កណ្តាលក្រុង"? (កណ្តាលក្រុងត្រូវការសមាគមពាណិជ្ជករអាស៊ីដូចនៅខបពលសគ្វែដែរ) ។ ខារ៉ន ប៉ែជីរ៉ន មកពីសភាពាណិជ្ជកម្មសួរថា តើសភាគួរធ្វើអ្វី ដើម្បីជួយ(ចំណេះទីផ្សារគឺជាគំនិតថ្មីសម្រាប់ពាណិជ្ជករខ្មែរជាច្រើន) ។ អនុសេនីយ ឯក រីកឆឺតសិន និយាយថា លោកសង្ឃឹមនឹងបាននិយាយជាមួយ លី នៅថ្ងៃមុខដើម្បីឱ្យដឹងពីនាងនឹងភ្ញៀវរបស់នាងយល់ឃើញអំពីសន្តិសុខនៅកណ្តាលក្រុងឡូវែល ។ **តទៅទំព័រទី ០៨**



ខេវិន ខហ្វលិន



ខារ៉ុន ប៉ែជីរ៉ុន



អនុសេនីយឯក រីកឆឺតសិន

Several follow-up speakers responded to Lee. Kevin Coughlin asked how the city could do more to increase customer traffic between established businesses like Cupples Square and those in downtown ("downtown needs and Asian Business Association like Cupples Square has"). Karon Bergeron from the Chamber of Commerce asked what the Chamber could do to assist ("Marketing is a new concept for many Cambodian business owners"). And Captain Richardson said he hoped to speak with Lee afterwards about the perception she and her customers have about safety in downtown Lowell. **Continued to Page 08**

ព័ត៌មានអន្តរជាតិ

# ជីវិតអ្នកបើកយន្តហោះម្នាក់ត្រូវគេដុតទាំងរស់នៅ ជោរ ឌីន

●●●ប្រឈមមុខនឹងភេរវករអ៊ីស្លាម"អាស៊ីស" ដែលបង្កើនការគម្រាមកំហែងលើសកលលោកកាន់តែខ្លាំងឡើងៗនឹងការបន្ទោសពីគណបក្សសាធារណរដ្ឋកាន់តែធ្ងន់ធ្ងរឡើងៗលោកប្រធានាធិបតីអាមេរិកាំងបានសម្រេចចិត្តស្នើទៅសភាសុំការអនុញ្ញាតិឱ្យប្រើកងទ័ពនៅមជ្ឈឹមបូព៌ា ។ គេសង្ឃឹមថា សភានឹងផ្តល់ភ្លើងខៀវឱ្យលោកប្រធានាធិបតី បារ៉ាក អូបាម៉ា នៅសប្តាហ៍ក្រោយនេះហើយ ។

ទាហានអ្នកបើកយន្តហោះប្រទេស ជោរ ឌីន ម្នាក់ឈ្មោះ មូ អាធ កាស៊ុំស្បេហ៍ Muath Kaseasbeh អាយុ២២ឆ្នាំ បានបើកបរយន្តហោះចុំន F-16ត្រូវក្រុមអ៊ីស្លាម isis បាញ់ធ្លាក់នៅប្រទេសស៊ីរី (Syria)នឹងត្រូវបានចាប់ខ្លួន កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ។ រហូតមកដល់ថ្ងៃទី២៩ខែមករា ឆ្នាំ២០១៥ រដ្ឋអ៊ីស្លាមបានស្នើឱ្យយកលោកស្រី សាជីដា មូបារ៉ាក់ អែររីុលហារ៉ី (Sajida Mubarak al- Rishawi)ដែលជាអ្នកដាក់គ្រាប់បែកនៅសណ្ឋាគារ អេមម៉ែន (Amman) នៅទីក្រុងសាកដាង(Jordan) កាលពីឆ្នាំ២០០៥ ។

ត្រូវរងការកាត់ទោសឱ្យជាប់ពន្ធនាគារមួយជីវិតឱ្យយកលោកស្រី សាជីដា មកប្តូរយកអ្នកបើកយន្តហោះ មូ អាធ ឱ្យបានមុនពេលថ្ងៃលិចថ្ងៃទី២៩ មករា ។

ប៉ុន្តែតាមរយៈទូរទស្សន៍ក្នុងរដ្ឋ ជោរឌីន បានបញ្ជាក់ថា : លោក មូអាធ អ្នកបើកយន្តហោះត្រូវបានគេសម្លាប់នៅថ្ងៃទី៣ មករា រយៈពេល១ខែកន្លងមករួចទៅហើយ ។ លោកប្រធានាធិបតីសហរដ្ឋអាមេរិក បារ៉ាក់ អូបាម៉ា បានថ្លែងថា: វីដេអូការសម្លាប់លោក មូអាធ កាស៊ុ ស្បេហ៍ បូជាយញ្ញ គឺជាការបង្ហាញឱ្យឃើញនូវភាពកាចសាហាវឃោរឃៅរបស់រដ្ឋអ៊ីស្លាម isis លោកប្រធានាធិបតីបានបន្តទៀតថា : ធ្វើបដិរូបកម្មភាពក្លាហានរបស់លោក កាស៊ីស្បេហ៍ ជាកូនប្រុសភក្តីភាពរបស់ប្រទេសជោរឌីន ជូនជាកិត្តិយសដល់ក្រុមគ្រួសារក្នុងប្រទេសដែលបានបំពេញកិច្ចការឃោសនាក្នុងរយៈពេល៧ឆ្នាំ ។

លោកប្រធានាធិបតី និងអនុប្រធានាធិបតី ស.រ.អា អូបាម៉ា និងជោ ប៊ីឌីន (Joe Biden) បានជួបប្រជុំជាមួយព្រះរាជាប្រទេស ជោ ឌីន អាប់ឌូល្លាហ៍ ម៉ែត (Abdullah Met) នៅថ្ងៃទី៣ កុម្ភៈ ២០១៥ បានសន្យាផ្តល់អំណោយដល់ប្រទេសជោរឌីនទ្វេរដងដែលធ្លាប់មានពីមុនមកដោយរង់ចាំការអនុវត្តពីរដ្ឋសភាតម្លើងថវិកាពី៦០០លានដុល្លារដល់១០០០លានដុល្លារ ។




គួររំលឹកផងដែរថា កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ២០១៤ រដ្ឋឥស្លាម isisបានចាប់ជីវិតជនជនជប៉ុនពីរនាក់ គឺលោក កែនជី ហ្គតូ (Kenji Goto) អាយុ៤៧ឆ្នាំ និងលោក ហារូណា យូកាវ៉ា (Haruna Yukawa) អាយុ៤២ឆ្នាំ រដ្ឋឥស្លាមបានជីវិតទារលុយ២០០លានដុល្លារ ក្នុងរយៈពេល៧២ម៉ោងចំនួនលុយ២០០លានដុល្លារស្មើនឹងចំនួនលុយដែលប្រទេសជប៉ុនសន្យាផ្តល់ជាអំណោយដល់បណ្តាប្រទេសរងគ្រោះដោយយោធានៃរដ្ឋឥស្លាមធ្វើទុក្ខទារុណកម្ម។

លោកនាយករដ្ឋមន្ត្រីប្រទេសជប៉ុន ស៊ីនសូ អេប៊ី (Shinzo Abe)បានកោះប្រជុំជាបន្ទាន់ទាំងកណ្តាលរាត្រីថ្ងៃទី២៤ មករា អង្គប្រជុំបានសម្រេចមតិជាឯកច្ឆន្ទមិនព្រមផ្តល់លុយឱ្យជនចាប់ជីវិត និងស្នើឱ្យលែងជនរងគ្រោះទាំងពីររូបមកវិញភ្លាម ។

យោធារដ្ឋឥស្លាមមិនព្រមដោះលែងរួចបានសម្លាប់ជនជាតិជប៉ុនអ្នកដើរផ្សងព្រេងទាំងពីរនាក់នោះក្រោយពីកំណត់៧២ម៉ោងដែលគេបានកំណត់ ។

លោកប្រធានាធិបតីស.រ.អា បារ៉ាក់ អូបាម៉ា បានថ្លែងនៅក្នុងករណីសម្លាប់លោក យ៉ាកាវ៉ា និងលោក ហ្គូតូនោះថា : យើងនិងប្រកៀកស្មាសម្ព័ន្ធមិត្តជប៉ុនធ្វើការជាមួយគ្នា ដើម្បីចាប់ពួកឃាតករទាំងនោះមកផ្តន្ទាទោស ៕

**ថាច់ វណ្ណា**

**ដកស្រង់ពីប្រភពព័ត៌មាន** N/R




# រោងជាង រចនា

**LEGEND AUTO BODY INC.**

អាស័យដ្ឋាន 115 Rock St. #7 Lowell, MA 01854

សូមទំនាក់ទំនង **អាដាំ វ៉ា** : **978-458-2085**

**ជួសជុលយានយន្តលោកអ្នក្រេបកបដោយគុណភាព**

Lowell Finest Quality of Body Work

**មានបម្រើ**

- ជួសម៉ាស៊ីនយានយន្ត
- ប្រភេទយានយន្តក្នុង និងក្រៅប្រទេស

**តួយានយន្ត**

- បញ្ជាក់ប័ណ្ណធានារ៉ាប់រងទទួលស្គាល់ដោយរដ្ឋ

**ដឹកឡានត្រូវចថូវ៍** 978-815-9957 (ខេ-ស៊ី)






LEGEND

**AUTO BODY INC.**

**(978) 458-2085**

**Services**

- Auto Body
- Auto Mechanics
- Foreign and Domestics
- State and Insurance Certified

Towing - **978-815-9957** (K.C)



**115 Rock St. Unt #7 Lowell, MA 01854**

# ឱកាសរៀនតម្បាញ

សារមន្ទីរប្រវត្តិវាយនភណ្ឌអាមេរិកាំង ផ្នែកតម្បាញក្រុងឡូវែលបានបើកថ្នាក់បង្រៀននៅម៉ោង១០-១២ព្រឹកថ្ងៃទី១៣/១៧កុម្ភៈ នឹងថ្ងៃទី២៧ ខែមិនា ជាឱកាសល្អសម្រាប់ប្រជារាស្ត្រខ្មែរជាច្រើនធ្លាប់មានបទពិសោធន៍ជំនាញខាងតម្បាញគ្រឿងសម្លៀកបំពាក់តាមប្រពៃណីខ្មែរសម្រាប់អាពាហ៍ពិពាហ៍សម្រាប់បុណ្យចូលឆ្នាំថ្មី និងបុណ្យផ្សេងៗទៀត តាមប្រពៃណីពុទ្ធសាសនា ។

ប្រសិនបើអស់លោកអ្នកមានចិត្តចង់រៀនតម្បាញ សូមអញ្ជើញចុះឈ្មោះនៅសារមន្ទីរប្រវត្តិវាយនភណ្ឌ ទូរស័ព្ទលេខ : ៩៧៨-៤៤១-០៤០០

## American Textile History Museum

**Lowell :** The American Textile History Museum knitting and weaving classes are being offered from 10Am-12Pm February 13/27 and March 27.2015. For many Cambodians, weaving is a traditional skill of great demand for today traditional clothes for special occasions such as wedding, Buddhist temple, and Cambodian New Year celebration.

If you like to weave and want to learn how, register your class by calling American Textile History Museum at 978-441-0400





រៀនត្បាញនៅឡូវែល

## តមកពីទំព័រទី ០១ រាត្រីសមោសរសម្លៀកបំពាក់រៀបការ...

តាំងពីរាប់រយឆ្នាំមកហើយ ដែលសព្វថ្ងៃសង្គមថ្មីកំពុងតែស្វះស្វែងរកអាថិកំបាំងនៃលំអររបស់មនុស្សមិនដែលស្លាប់ស្លល់នៅឡើយ ។

ស្ត្រីអាស៊ី៥រូបបានចាប់ដៃគ្នាជាឱកាសដំបូងបង្អស់ខិតខំបង្កើតរាត្រីសមោសរលក្ខណៈលើកដំកើងពាណិជ្ជកម្មលើមុខរបរជាអ្នកឯកទេសខាងលំអរមនុស្សដោយយកវប្បធម៌ដ៏ខ្ពស់មកពីអាស៊ី ហើយបង្ហាញជូនសាធារណជនប្រកបដោយជោគជ័យ ។ នៅសហគមន៍អាស៊ីមានហាងសំលៀកបំពាក់វប្បធម៌ជាតិនឹងសំលៀកបំពាក់គ្រឿងកើតព្រោងព្រាតតែរាត្រីសមោសរថ្ងៃទី៧កុម្ភៈ នៅឡូវែលនេះ ប្រាកដជាដំណើរបែបថ្មីទៅរកបច្ចេកទេស"ទីផ្សារ"សម័យដែលសង្គមបច្ចុប្បន្នកំពុងប្រើ ។ វានឹងផ្តល់យុវជន-យុវតីអាស៊ីនៅបរទេសត្រឡប់មកស្រឡាញ់ភាពសង្ហាររបស់ជាតិសាស្ត្រខ្លួនវិញបាន ។

បន្ថែមពីនេះ ការចូលរួមជាការតាំងតុពិពណ៌ផលិតផលអាស៊ីច្រើនមុខទៀត ជាគំនិតដ៏ប្រសើរមួយទៀត ដែលនាំឱ្យមានការរួមសម្បាច់គ្នាទៅរកផលប្រយោជន៍រួមនៃទីផ្សារសម័យរបស់ពាណិជ្ជករសម័យថ្មី ៕



Serina Van-Danh, Champa Pang, Linda Nom, Dawn Simmons, Sim Som
Srey Photography






# បទសម្ភាសន៍ជាមួយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ

**ដោយ : ពិន សំខុន**

*ថ្ងៃទី ២៨ មករា ២០១៥ នៅឡូវែល - ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ធម្មិកោ បានចូលជាថ្នាក់ដឹកនាំរបស់គណបក្សសង្គ្រោះជាតិ តែព្រះអង្គធ្លាប់ជាថ្នាក់ដឹកនាំកំពូលនៃគណបក្សហ៊្វុនស៊ិនប៉ិច តើព្រះអង្គយល់យ៉ាងណាពីគណបក្សរាជានិយម ? ហេតុអ្វីក៏ព្រះអង្គប្តូរពីហ៊្វុនស៊ិនប៉ិចមកសង្គ្រោះជាតិ ? តើព្រះអង្គមានសង្ឃឹមប៉ុណ្ណាលើជ័យជំនះរបស់គណបក្សសង្គ្រោះជាតិ ? ព្រះអង្គបានផ្តល់បទសម្ភាសន៍ថ្មីមួយស្តីពីរឿងទាំងនេះដូចតទៅ :*


ព្រះអង្គម្ចាស់ធម្មិកោ ផ្តល់បទសម្ភាសន៍ដល់ ពិន សំខុន

**សួរ:** ថ្វាយបង្គំព្រះអង្គម្ចាស់ធម្មិកោ ! ទូលបង្គំដឹងថា ព្រះអង្គធ្លាប់ជាឧបការី ឬទីប្រឹក្សារបស់សម្តេចនរោត្តម សីហនុ តើព្រះអង្គម្ចាស់បំរើព្រះមហាក្សត្រនរោត្តម ស៊ីហនុ ក្នុងតួនាទីអ្វី? ហើយចាប់ពីពេលណាមក?

**ស.ធម្មិកោ:** ជាដំបូងខ្ញុំសូមជំរាបថា បងប្អូនហៅឈ្មោះខ្ញុំថា ធម្មិ"កោ" តាមពិតទៅជាពាក្យបាលី "កដាក់ស្រះអោ" គេអានថា "គោ" ដូច្នេះឈ្មោះខ្ញុំគេអានថា"ធម្មិគោ"...ចា! ខ្ញុំដង្ហែព្រះ-មហាក្សត្រនរោត្តម សីហនុ ចាប់តាំងពីឆ្នាំ១៩៧៩ ក្នុងតួនាទីជាអ្នក"ទំនាក់ទំនងសារព័ត៌មាន" នៅទីក្រុងប៉ារីសនៃប្រទេសបារាំង.. ក្រោយមកនៅឆ្នាំ១៩៨៣ លោកបានតែងតាំងខ្ញុំជាព្រះរាជដំណាងរបស់ព្រះអង្គនៅសភាអឺរ៉ុបដែលមានទីតាំងនៅ"ស្ត្រាសបួរ"នៃប្រទេសបារាំងដែរ គឺនៅពេលមានរដ្ឋាភិបាលនៃសម្ព័ន្ធភាពត្រីភាគីខ្មែរកើតឡើង រវាងហ៊្វុនស៊ិនប៉ិច-ចលនារំដោះលោកតាសឺន សាន-នឹងកម្ពុជាប្រជាធិបតេយ្យ រហូតដល់ខ្ញុំលាលែងនៅឆ្នាំ១៩៨៨ ។

**សួរ:** តើពេលនោះ នៅសភាអឺរ៉ុបការងារព្រះអង្គធ្វើអ្វីខ្លះ?

**ស.ធម្មិកោ:** ការងារខ្ញុំមានតែមួយគត់ គឺទំនាក់ទំនងជាមួយសារព័ត៌មានជាមួយសមាជិកសភាជាតំណាងរាស្ត្រ មានបារាំង បែលហ្ស៊ិក អាល្លឺម៉ង់ អង់គ្លេស ។ល។... ដើម្បីផ្តល់ព័ត៌មានពីស្ថានភាពនៅកម្ពុជាដែលពេលនោះកម្ពុជាបានត្រូវកាន់កាប់ដោយប្រទេសសាធារណរដ្ឋសង្គមនិយមវៀតណាមដោយចំហរពីឆ្នាំ១៩៧៩-៩១ ហើយដែលខុសគ្នាពីសព្វថ្ងៃនេះ គឺកាន់កាន់ដោយសម្ងាត់ គឺខ្ញុំផ្តល់ព័ត៌មានពន្យល់ពីស្ថានភាពនៅកម្ពុជាពេលនោះឱ្យទៅគេ ហើយសុំគេឱ្យមានការគាំទ្រ ។

**សួរ:** តើពេលនោះ ព្រះអង្គនៅប៉ារីស ឬក៏នៅស្ត្រាសបួរ ?

**ស.ធម្មិកោ:** ចា! នៅប៉ារីសទេ តែដល់មានការងារត្រូវធ្វើដូចជាមានកិច្ចប្រជុំជាដើមរដ្ឋា-ភិបាលត្រីភាគីគេជួលផ្ទះ នឹងមានកន្លែងធ្វើការនៅទីនោះ ទើបខ្ញុំទៅទីនោះ ។

**សួរ:** បន្ទាប់មកព្រះអង្គបាត់ខ្លួនជាង១០ឆ្នាំ តែព្រះអង្គមានបន្ទូលថា នៅឆ្នាំ២០០០ ព្រះអង្គត្រឡប់ទៅបំរើព្រះករុណា សីហនុ វិញ តើក្នុងតួនាទីអ្វីទៅ?

**ស.ធម្មិកោ:** ព្រះអង្គបានសព្វព្រះរាជហឫទ័យតែងតាំងខ្ញុំជាព្រះរាជលេខាផ្ទាល់ ខ្ញុំជាអ្នកសរសេរលិខិត ឬសុន្ទរកថារបស់ព្រះអង្គជាពិសេស ជាភាសាបារាំងឬអង់គ្លេស ។

**សួរ:** តើមានអ្នកណានៅត្រួតលើការងារព្រះអង្គដែរ ឬទេ?

**ស.ធម្មិកោ:** អត់ទេ មានតែព្រះកូណាសម្តេចឪ តែប៉ុណ្ណោះ

**សួរ:** ដល់ពេលព្រះកូណាលោកសុគតទៅ តើព្រះអង្គមាននៅបន្តធ្វើការថ្វាយ សម្តេចព្រះរាជអគ្គមហេសី តទៅទៀតទេ ?

**ស.ធម្មិកោ:** បន្ទាប់ពីព្រះកូណាសម្តេចឪលោកសុគតទៅ ព្រះកូណានរោត្តម សីហមុន្នីបានសព្វព្រះរាជហឫទ័យផ្ទេរខ្ញុំឱ្យទៅកាន់ព្រះរាជខុទ្ទកាល័យសម្តេចម៉ែ ទៅជួយលោក ដូចដែលខ្ញុំធ្លាប់ធ្វើនៅព្រះរាជខុទ្ទកាល័យសម្តេចឪអ៊ីចឹងមែន!

**សួរ:** តើបន្ទាប់មកព្រះអង្គមានក្លាយជាទីប្រឹក្សារបស់ព្រះកូណា សីហមុន្នី មែនទេ?

**ស.ធម្មិកោ:** ខ្ញុំមិនដែលធ្វើជាទីប្រឹក្សាព្រះកូណា សីហមុន្នី ទេលើកលែងតែពេលមួយនោះ ក្នុងរយៈពេល៤-៥ខែ នៃឆ្នាំ២០០៥ ព្រះអង្គសព្វព្រះរាជហឫទ័យឱ្យខ្ញុំបានមកជួយធ្វើគេហទំព័រថ្វាយលោកដោយសារខ្ញុំមានជំនាញខាងវិទ្យាសាស្ត្រព័ត៌មានក្រៅពីពេលនោះខ្ញុំមិនដែលបំរើលោក ទេ

**តទៅទំព័រទី ១១**

GREATER LOWELL
CHAMBER OF COMMERCE

131 Merrimack Street – Lowell MA
978-459-8154
www.greaterlowellchamber.org

A resource for your business or organization!
Networking Events
Seminars
Resources
TV & Radio Shows
And more!

សភាពាណិជ្ជកម្មនៅក្រុងឡូវែល គឺជាធនធានមួយសម្រាប់មុខរបរ ឬសម្រាប់អង្គការរបស់លោកអ្នក
ព្រឹត្តិការណ៍ទំនាក់ទំនង
សន្និសីទ
រកធនធាន
កម្មវិធីទូរទស្សន៍ និងវិទ្យុ
និងនៅមានច្រើនទៀត

NOW HIRING!
LAVELLE MACHINE

Lavelle Machine, a leading manufacturer in the medical industry is seeking qualified, motivatedindividuals to join our team in the following positions:

Experienced CNC Lathe Operator
Hands on-CNC Turning individual needed for set-up and operate:
• Able to work within tight tolerances • Well versed in multi-axis Turn machines
• Programming experience a plus •5+ year's experience preferred

Quality Control Inspector
Position involves inspection of incoming, in-process and final inspection on precision-machined .000x's components.

Demonstrates expertise in:
• Inspection experience with calipers, thread gages, plug gages, spring testing and comparators • GD & T • CMM • Calibration tools & gages
• Inspection of tight tolerance mechanical components • Vision System
• Components and assemblies using various measuring devices
• 5+ Years of Experience Preferred

Attention to detail, multi-tasking, accuracy and excellent interpersonal skills a must.

Applicants may send resumes to: HR@lavellemachine.com or fax to: 978-692-5774

Lavelle Machine is an Equal Opportunity Employer and offers excellent benefits including 401(k), profit sharing, etc. ISO 9001 and 13485 Registered

## តមកពីទំព័រទី ១០ បទសម្ភាសន៍ជាមួយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ..

**សួរ:** ខ្ញុំបានជួបព្រះអង្គនៅព្រះបរមរាជវាំង កាលពីខែ សីហា មុន តើព្រះអង្គពុំមែនកំពុងបំរើព្រះកូណា សីហមុន្នី ទេឬ ?

**ស.ធម្មិកោ:** ខ្ញុំឥតមានតួនាទីអ្វីទេ ពេលនោះខ្ញុំនៅវាំងដោយចៃដន្យ ខ្ញុំមានបន្ទប់ខ្ញុំមួយនៅក្នុងវាំង តែពេលណាខ្ញុំមិននៅសៀមរាបទេ ខ្ញុំមកភ្នំពេញ ខ្ញុំទៅសំណាក់នៅបន្ទប់របស់ខ្ញុំ ។

**សួរ:** ព្រះអង្គមានដើមកំណើតនយោបាយពីហ៊្វុនស៊ិនប៉ិចពីនយោបាយសម្តេចនរោត្តម សីហនុ ហេតុអ្វីក៏ព្រះអង្គបានជាសម្រេចព្រះទ័យចូលរួមជាមួយគណបក្សសង្គ្រោះជាតិ?

**ស.ធម្មិកោ:** មានបុព្វហេតុជាច្រើនដែលសំខាន់មានតែ២ទេ ទី១ គណបក្សកាន់អំណាចបច្ចុប្បន្នមិនស្មោះត្រង់នឹងរាជានិយមទេ ខ្ញុំបានឃើញច្បាស់នៅពេលសម្តេចឪចូលទិវង្គត់ទៅ គឺនៅថ្ងៃដង្ហែព្រះបរមសពព្រះបាទរតនកោដ្ឋមកពីប្រទេសចិនគណបក្សប្រជាជនមានការភ្ញាក់ផ្អើលស្មានថា ស្រុកខ្មែរអស់ស្តេចនឹងរាជានិយមមិនទឹកស្មានថានឹងមានប្រជាពលរដ្ឋរាប់លាននាក់មកសំដែងការគោរពនឹងសោកស្តាយសម្តេចឪតាមផ្លូវពីចំណតយន្តហោះមកដល់ព្របរមរាជវាំងនោះទេ មនុស្សរាប់លាននាក់បានមកបង្ហាញខ្លួនមកគោរពព្រះបរមសពនាថ្ងៃបន្តបន្ទាប់ដោយមិនរាប់ភ្ញៀវបរទេសដំណាងរដ្ឋនានាផងទៀត ខ្ញុំបានឃើញមនុស្សជាច្រើនទៀតបានទទួលការហាមឃាត់មិនឱ្យចូលមកគោរពព្រះបរមសពទេ នៅលើការមិនស្មោះត្រង់នេះហើយដែលខ្ញុំសម្រេចចិត្តចូលក្នុងឆាកនយោបាយនោះ

**សួរ:** ចុះទី២?

**ស.ធម្មិកោ:** បុព្វហេតុមិនស្មោះត្រង់នេះស្ថិតនៅលើនយោបាយសព្វថ្ងៃរបស់លោក ហ៊ុន សែន ដែលធ្លាប់ប្រកាសថា លោកអនុវត្តនយោបាយសង្គមរាស្ត្រនិយម តែខ្ញុំឃើញថា នយោបាយក្នុងសង្គមក្នុងស្រុកក្រៅស្រុកដើរផ្ទុយស្រឡះពីសង្គមរាស្ត្រនិយមដែលធ្វើឱ្យខ្ញុំសម្រេចចូលឆាកនយោបាយបន្តមាគ៌ាព្រះអង្គតទៅទៀត ហើយមានតែគណបក្សសង្គ្រោះជាតិទេ ដែលអាចផ្តល់លទ្ធភាពឱ្យខ្ញុំធ្វើការនេះសម្រេចបាន ។

**សួរ:** តើព្រះអង្គជឿថា គណបក្សសង្គ្រោះជាតិអាចនឹងគាំទ្ររាជានិយមនឹងនយោបាយសម្តេចសីហនុឬទេ ?

**ស.ធម្មិកោ:** សំនួរមិនស្ថិតលើថា "គាំទ្រ ឬមិនគាំទ្រទេ" តែស្ថិតលើថា តើគណបក្សសង្គ្រោះជាតិ "ប្រឆាំងនឹងរាជានិយមឬអត់" ត្រង់នេះមានហេតុជាច្រើនបង្ហាញថានយោបាយឯកឧត្តម សម រង្ស៊ី មិនប្រឆាំងទេ ពីព្រោះលោកជាអតីតសមាជិកស្ថាបនិករបស់គណបក្សហ៊្វុនស៊ិនប៉ិចឆ្នាំ១៩៨១មុនសម្តេចក្រុមព្រះដែលចូលហ៊្វុនស៊ិនប៉ិចឆ្នាំ ១៩៨៣ រីឯទ្រង់ សេរីវុឌ្ឍ នៅឆ្នាំ១៩៨៦ ដែលជាស្តេចធំៗទៅទៀត។ រីឯអ្នកបោះឆ្នោតទៀតសោត កាលពីឆ្នាំ១៩៩៣ ហ៊្វុនស៊ិនប៉ិចបាន ៥៨ អាសនៈដល់ឆ្នាំ១៩៩៨ គណបក្សហ៊្វុនស៊ិនប៉ិចបាន ៤៣អាសនៈ រីឯគណបក្ស សម រង្ស៊ី បាន១៥ អាសនៈ គឺជាឆ្នោតដែលបែកពីហ៊្វុនស៊ិនប៉ិចទៅទាំងអស់បាន ៥៨ដដែលដល់ឆ្នាំ២០១៣ឆ្នោត គណបក្សសង្គ្រោះជាតិគឺបានមកពីលោក សម រង្ស៊ី ជានិមិត្តរូបនៃហ៊្វុនស៊ិនប៉ិចនឹងលោក កឹម សុខា ជានិមិត្តរូបនៃគណបក្សលោកតាសឺន សាន រួមគ្នាជាដំណាងឱ្យសីហនុនិយមដដែល រីឯលទ្ធផលដែលគេបង្ហាញនោះគ្រាន់តែជាលេខតែប៉ុណ្ណោះ ។

**សួរ:** ឥឡូវសម្តេចក្រុមព្រះដឹកនាំគណបក្សហ៊្វុនស៊ិនប៉ិចចេញមកវិញហើយ ព្រះកូណា សីហនុ ក៏ធ្លាប់គាំទ្រទ្រង់ រណឫទ្ធិ ឱ្យកាន់អំណាចជាគណបក្សរាជានិយមដែរ តែការគាំទ្ររបស់ទ្រង់បែរជាកាន់តែតិចទៅៗ តើព្រះអង្គមើលទៅអនាគតនៃគណបក្សរាជានិយមទៅអនាគតមានរូបភាពរបៀបណាទៅ ?

**ស.ធម្មិកោ:** ខ្ញុំធ្លាប់ទូលស្តេចក្រុមព្រះដែរថា ឱ្យឈប់ប្រើពាក្យគណបក្សរាជានិយមតទៅទៀតទៅ ពីព្រោះនៅព្រះរាជាណាចក្រប្រជាធិបតេយ្យធំៗគេឥតមានគណបក្សរាជានិយមទេ ដូចជាចក្រភពអង់គ្លេស ប្រទេសស៊ុយអែដ ប្រទេសបែលហ្សិក ជាដើម... ខ្ញុំចង់ឃើញនៅប្រទេសកម្ពុជាមានប្រជារាស្ត្រជារាជានិយមរួចទៅហើយ មិនមែនបានន័យថា អ្នកណាបោះឆ្នោតឱ្យហ៊្វុនស៊ិនប៉ិច ទើបជាអ្នករាជានិយម រីឯអ្នកឯទៀត មិនមែនជារាជានិយមនោះទេ... រាជានិយមនៃប្រទេសយើង គឺការទ្រទ្រង់"សេរីភាព" ទ្រទ្រង់ "លទ្ធិប្រជាធិបតេយ្យ"ទ្រទ្រង់ "យុត្តិធម៌" ដែលប្រទេសរាជានិយមធំៗទាំងនោះ អនុវត្តន៍ហើយបានផ្តល់ភាពចំរុងចំរើននឹងស្ថេរភាពដល់ប្រទេសគេយ៉ាងរឹងមាំ... ខ្ញុំបានទៅតាមជនបទស្រែចំការប្រជារាស្ត្រនៅស្រឡាញ់រាជានិយមច្រើនណាស់ តែគេបោះឆ្នោតឱ្យសង្គ្រោះជាតិ ពីព្រោះសង្គ្រោះជាតិកាពារគោលជំហ៊រ "សិទ្ធសេរីភាព" ជំហ៊រ"ប្រជាធិបតេយ្យ"ដែលរាជានិយមត្រូវតែការពារ

*(សូមរង់ចាំអានភាគបន្តនៃបទសម្ភាសន៍នេះនៅលេខក្រោយទៀត)*



ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសែតអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ពុធ ទី១០ ខែកុម្ភៈ ឆ្នាំ២០១៥

## អង្គការសិទ្ធិមនុស្សនិយាយថា កូនក្រមុំខ្មែរដែលរងការរំលោភបំពាននៅចិនមានចំនួនកើនឡើងគួរឱ្យបារម្ភ

**ដោយ គុជ ណារ៉េន** | **JANUARY 29, 2015**

យោងតាមបណ្តាអង្គការសិទ្ធិមនុស្សដែលកាលពីឆ្នាំមុនបានជួយធ្វើមាតុភូមិនិវត្តកូនក្រមុំខ្មែរជិត៥០នាក់ ដែលត្រូវគេជួញដូរនៅបរទេស ឬត្រូវបានទាក់ទាញទឹកចិត្តដោយការសន្យាថាពួកគេនឹងមានជីវភាពធូរធារនោះ ចំនួនស្ត្រីខ្មែរដែលបានរងការរំលោភបំពានក្រោយរៀបការជាមួយប្តីនៅក្នុងប្រទេសចិន កំពុងកើនឡើងគួរឱ្យកត់សម្គាល់។

អង្គការសិទ្ធិមនុស្សអាដហុក និងអង្គការលីកាដូបានលើកឡើងកាលពីម្សិលមិញថា ខ្លួនបានជួយស្ត្រីចំនួន៤៩នាក់ឱ្យវិលត្រឡប់ពីប្រទេសចិនមកកម្ពុជាវិញនៅក្នុងឆ្នាំ២០១៤ បើប្រៀបធៀបនឹងចំនួន២៩នាក់នៅក្នុងឆ្នាំ២០១៣។

លោកស្រី ឆន សុគន្ធា ប្រធានកម្មវិធីសិទ្ធិស្ត្រី និងកុមារនៃអង្គការអាដហុកបានមានប្រសាសន៍ថា អង្គការអាដហុកបានជួយស្ត្រី២១នាក់ក្នុងចំណោមស្ត្រីទាំងនោះកាលពីឆ្នាំមុន បើប្រៀបធៀបនឹងចំនួនតែបួននាក់ក្នុងឆ្នាំ២០១៣។

លោកស្រីបានមានប្រសាសន៍ទៀតថា "ជនរងគ្រោះទាំងនេះត្រូវបានទាក់ទាញទឹកចិត្តឱ្យធ្វើដំណើរទៅប្រទេសចិនជាមួយការសន្យាផ្តល់ការងារមានប្រាក់ខែខ្ពស់ និងរៀបការជាមួយប្តីចិនអ្នកមាន។ ប៉ុន្តែទីបំផុតពួកគេត្រូវគេលក់ឱ្យទៅបុរសៗចិនដែលពេលខ្លះលក់ក្នុងតម្លៃពី១៥.០០០ដុល្លារទៅ២០.០០០ដុល្លារឱ្យធ្វើជាទាសករសិច។ វាជាការជួញដូរមនុស្សមួយប្រភេទក្រោមលេសរៀបការ"។

លោក អំ សំអាត ប្រធានគ្រប់គ្រងផ្នែកបច្ចេកទេសស៊ើបអង្កេតនៅអង្គការសិទ្ធិមនុស្សលីកាដូ បានមានប្រសាសន៍ថា អង្គការរបស់លោកបានជួយនាំស្ត្រី២៨នាក់ទៀតឱ្យត្រឡប់មកប្រទេសកម្ពុជាវិញ បើប្រៀបធៀបនឹងចំនួន២៥នាក់កាលពីឆ្នាំ២០១៣។

លោកមានប្រសាសន៍ថា "ពួកគេភាគច្រើនបានទទួលរងការរំលោភបំពានផ្លូវកាយ និងផ្លូវភេទ"។ លោកបានបន្ថែមថា លោកចាត់ទុកស្ត្រីទាំងអស់នេះថា ជាជនរងគ្រោះនៃការជួញដូរ។

ច្បាប់ប្រឆាំងការជួញដូរមនុស្សរបស់ប្រទេសកម្ពុជាដែលត្រូវបានអនុម័តកាលពីឆ្នាំ២០០៨ ចាត់ទុកការនាំអ្នកណាម្នាក់ចេញពីប្រទេសថាគ្មានច្បាប់ទម្លាប់ត្រឹមត្រូវ ប្រសិនបើធ្វើឡើង "តាមមធ្យោបាយប្រើកម្លាំងការគំរាមកំហែង ការបោកបញ្ឆោត ការបំពានកម្លាំង ឬការលួងលោម។ ការយល់ព្រមរបស់ជនរងគ្រោះមិនពាក់ព័ន្ធគ្នាទេ"។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជាបានមានប្រសាសន៍កាលពីម្សិលមិញថា ក្រសួងរបស់លោកបានកត់ត្រាចំនួនស្ត្រីដែលត្រូវបានធ្វើមាតុភូមិនិវត្តនៅក្នុងឆ្នាំ២០១៤មានចំនួនសរុប៥៨នាក់ ប៉ុន្តែបានមានប្រសាសន៍ថា ក្រសួងគ្មានតួលេខសម្រាប់ឆ្នាំ២០១៣ទេ។

លោកបានមានប្រសាសន៍បន្តថា "យើងជឿថា តទៅទំព័រទី ១៣

## Human rights organizations say the Khmer bride who suffered abuse in China were up worrying

**KUCH NAREN | JANUARY 29, 2015**

According to human rights organizations, who last year helped to repatriate Khmer bride of nearly 50 people who have been trafficked abroad or attract motivated by the promise that they will live better lives, Khmer women who have suffered abuse After marrying her husband in China is increasing remarkably.

Rights group Adhoc and Licadho, said yesterday that it helped 49 women to come back from China Cambodia in 2014, compared with 29 in 2013.

Compatible Sokuntheary head of the rights of women and children of the rights group Adhoc, said that the organization Adhoc helped 21 women among those women last year, compared to only four in 2013.

She said, "These victims are attractive incentives to travel to China with pledges higher paying job and married to your husband. But ultimately, they were sold to Chinese men who sometimes sell for from $ 15,000 to $ 20,000 serve as sex slaves. It is a type of human trafficking under the pretext of marriage. "

Ath investigative technical manager at Human Rights has said that his organization has helped 28 women back to Cambodia, compared to 25 in 2013.

He says, "Most of them have suffered physical abuse and sexual." He added that he considered all these women as victims of trafficking.

The law against human trafficking in Cambodia, which was approved in 2008, considered to bring someone out of the country without proper rules if made "way to use the threat of force, fraud, abuse strength or comfort. The consent of the victim was not involved. "

Kuong Cambodian Foreign Ministry spokesman, said yesterday that his ministry had recorded the number of women who are repatriation in 2014, a total of 58 people, but said that the ministry has no figures for 2013.

He said, "We believe there are more victims [in China] there quietly with brokers. "He further said that about 10 people have already been repatriated so far this year.

He also said that these figures rights conflicts with the figures of the Ministry of Foreign Affairs, but claimed Ministry figures.

He said that "non-governmental organizations working on the issue, just received a complaint from the victim or the victim's family, but They sent them to us because the government, which is able to deal with the relevant authorities China. "

The Foreign Ministry announced on Monday that two women from Prey Veng, Kandal and was sent back to Cambodia In that day.

According to a statement from the ministry yesterday said that an additional five women Capital is scheduled to arrive at 3 pm After being rescued by the consulate in the city of Guangzhou (Guangzhou), China. This statement suggests that these women are their families sent to marry Chinese men Jiangxi Province (Jiangxi), China.welfare.

## អត្ថបទវិភាគៈ ការគំរាមប្រើកម្លាំងមានឥទ្ធិពលលើវប្បធម៌សន្ទនា

**ដោយ អេឡិក វិល្លៀមមីនស៍** | **JANUARY 27, 2015**

បន្ទាប់ពីរយៈពេលប្រាំមួយខែបណ្តោយទៅតាមការប្រកាសអំពី "វប្បធម៌សន្ទនា" ថ្មីរបស់លោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងដែលនឹងត្រួសត្រាយផ្លូវឱ្យមានការប្តូររបបដោយគ្មានការបង្ហូរឈាមនោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានផ្អាកនៅដើមសប្តាហ៍នេះ។

លោក ហ៊ុន សែន បានមានប្រសាសន៍កាលពីថ្ងៃច័ន្ទសប្តាហ៍មុន ក្នុងពិធីប្រគល់សញ្ញាប័ត្រដល់និស្សិតនៅខេត្តស្វាយរៀងថា "ខ្ញុំសូមនិយាយឱ្យច្បាស់ និងសូមផ្តាំផ្ញើទៅឯកឧត្តម សម រង្ស៊ី ថា វប្បធម៌សន្ទនាលែងមានប្រសិទ្ធភាពហើយ។ អូខេទៅបានមិនចាំបាច់សន្ទនាអីទេ"។

នៅថ្ងៃដដែលនោះ នៅមូលដ្ឋានកងទ័ពជើងទឹកជ្រោយចង្វាក្រុងភ្នំពេញ លោក ទៀ បាញ់ រដ្ឋមន្ត្រីក្រសួងការពារជាតិដែលបម្រើការយូរមានសារទៅកាន់ទាហាននៃកងកម្លាំងប្រដាប់អាវុធកម្ពុជារឹតតែបង្ហាញច្បាស់ថែមទៀត។

លោកឧត្តមសេនីយ៍ ទៀ បាញ់ បានមានប្រសាសន៍ថា "កម្តៅកំពុងតែកើនឡើងដោយសារការប្រើវោហារសាស្ត្រ ការញុះញង់ឱ្យ និងឧការបង្កហេតុ...វាយប្រហារយ៉ាងខ្លាំងលើរដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជា ហើយពួកគេនិយាយថា មានតែគណបក្សសង្គ្រោះជាតិប៉ុណ្ណោះអាចផ្តួល តទៅទំព័រទី ១៤

## Text analysis yoga threatened to use force to influence the 'culture of dialogue'

**,BY E-MM MIN AIDS | JANUARY 27, 2015**

After six months, along with the announcement of the "culture of dialogue" Sam Rainsy, leader of the opposition, which will pave the way for a The regime change without bloodshed, Prime Minister Hun Sen suspended at the beginning of this week.

Hun Sen said on Monday last week student graduation ceremony in Svay Rieng province, "Let me be clear and Please give to Mr. Sam Rainsy cultural dialogue no longer effective. Okay unnecessary conversation all right. "

On the same day, at the Naval Base Chroy Minister Tea Banh Defense long to soldiers of the armed forces, even more clear.

Gen Tea Banh said that "heat is increased by the use of rhetoric to incite [and] provocations ... sharp attacks on government and the CPP, and they say that only party can beat the CPP and Hun Sen. ".

He added, "Before, we [the government] into the battle to end the war, but now it's not like that. However, we still need to have our position clear. " "They gathered some people and started to attack, and it all started with intense heat, so we have to hit back."

The next day Sam Rainsy shows being cracked this new culture is less divorce when asked about the threat Hun Sen to imprisonment parliamentary party.

Opposition leader, said in an interview, "My role, I believe that in order to avoid further confrontation any longer, and I do not **Continued to Page 18**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស | អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី | ច្បាប់ចេញផ្សាយថ្ងៃ ពុធ ទី១០ ខែកុម្ភៈ ឆ្នាំ២០១៥

# មន្ត្រីយោធា និងប៉ូលិសជាន់ខ្ពស់ទទួលបានការឡើងតំណែងក្នុងបក្ស

**ដោយ : មេឈ ដារ៉ា** | FEBRUARY 3, 2015

គណបក្សប្រជាជនកម្ពុជាកំពុងកាន់អំណាចបានស្វាគមន៍សមាជិកថ្មីចូលគណៈកម្មាធិការកណ្ដាលនៅថ្ងៃបញ្ចប់នៃមហាសន្និបាតគណបក្សរបស់ខ្លួនកាលពីថ្ងៃអាទិត្យដោយបញ្ចូលសមាជិកថ្មីជាច្រើននាក់ក្នុងជួរគណៈកម្មាធិការកណ្ដាលបក្សដែលសឹងតែបាត់បង់ការគ្រប់គ្រងអំណាចជាច្រើនទសវត្សរ៍របស់ខ្លួនក្នុងការបោះឆ្នោតជាតិចុងក្រោយនេះ។

ការបន្ថែមនេះកើនជាងពីរដងនៃសមាជិកគណៈកម្មាធិការកណ្ដាលគឺឡើងដល់៥៤៥នាក់ និងបញ្ចូលមន្ត្រីយោធា និងប៉ូលិសជាន់ខ្ពស់មួយចំនួនព្រមទាំងកូនប្រុសបីនាក់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ផងដែរ។

និយាយជាមួយអ្នកយកព័ត៌មាននៅពេលបិទមហាសន្និបាត លោក ខៀវ កាញារីទ្ធ រដ្ឋមន្ត្រីក្រសួងព័ត៌មានបានអួតអំពីការបន្ថែមស្ត្រី៤៥រូបចូលគណៈកម្មាធិការកណ្ដាល និងសមាជិក "វ័យក្មេង" ៧០រូបអាយុក្រោម៥០ឆ្នាំ។

ក្នុងចំណោមសមាជិក២៦៨នាក់ក្នុងបញ្ជីគណៈកម្មាធិការកណ្ដាលដែលដឹកនាំសមាជកាលពីថ្ងៃសុក្រ ២៧រូបបានទទួលមរណភាពចាប់តាំងពីគណៈកម្មាធិការនេះបានកោះប្រជុំចុងក្រោយកាលពីឆ្នាំ២០១៣ មួយរូបបានលាលែងចេញពីតំណែង និងបណ្ដេញចេញពីគណបក្សមួយរូប។

លោក កាញារីទ្ធ បានមានប្រសាសន៍ថា "យើងបានបន្ថែមសមាជិក ពីព្រោះសមាជិកចាស់កាន់តែចាស់និងទទួលមរណភាព។ យើងត្រូវជ្រើសរើសយុវជន ពីព្រោះចំនួន៥០ភាគរយនៃប្រទេសនេះមានអាយុតិចជាង៣០ឆ្នាំ ដូច្នេះយើងបានជ្រើសរើសយុវជនដែលមានបទពិសោធន...។ យើងត្រូវការអ្នកស្នងដែលមានសមត្ថភាពគ្រប់គ្រាន់"។

លោកបានមានប្រសាសន៍ថា គណបក្សមិនបានកែប្រែគណៈកម្មាធិការអចិន្ត្រៃយ៍ទេ ហើយថាប្រធានគណៈកម្មាធិការកណ្ដាលដែលមានជំងឺគឺលោក ជា ស៊ីម ប្រធានព្រឹទ្ធសភា ដែលមិនបានចូលរួមក្នុងមហាសន្និបាតនេះ ពីព្រោះកំពុងទទួលការព្យាបាលជំងឺនៅប្រទេសវៀតណាមនោះ បានទទួលអាសនៈរបស់លោកដដែល។

លោក កាញារីទ្ធ មិនបានប្រាប់ឈ្មោះនរណាម្នាក់ក្នុងចំណោមសមាជិកថ្មីរបស់គណៈកម្មាធិការកណ្ដាលនេះទេ។

ប៉ុន្តែបើយោងតាមបញ្ជីមួយបង្ហោះតាមគេហទំព័រព័ត៌មានភាសាខ្មែរក្នុងស្រុកបានឱ្យដឹងថា បញ្ជីនោះមានឈ្មោះកូនប្រុសទាំងបីនាក់របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងមនុស្សដ៏មានឥទ្ធិពលមួយចំនួនក្នុងជួរយោធានិងប៉ូលិសផងដែរ។

បញ្ជីនោះមានឈ្មោះលោក ឆៃ ស៊ីណារិទ្ធ ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុងដ៏មានអំណាចនៅក្រសួងមហាផ្ទៃ លោក ហ៊ីង ប៊ុនហៀង មេបញ្ជាការកងអង្គរក្សផ្ទាល់របស់លោកនាយករដ្ឋមន្ត្រី លោក ទូច ណារុថ ប្រធាននាយកដ្ឋានអង្គរក្សក្រសួងមហាផ្ទៃ លោក ម៉ក់ ជីតូ អគ្គស្នងការរងនៃអគ្គស្នងការដ្ឋាននគរបាលជាតិលោក ជួន សុវណ្ណ ស្នងការនគរបាលក្រុងភ្នំពេញ លោក រ័ត្ន ស្រ៊ាង មេបញ្ជាការកងរាជអាវុធហត្ថក្រុងភ្នំពេញ។

ការបន្ថែមសមាជិករបស់ពួកគេទំនងជាបញ្ឆេះឱ្យមានការរិះគន់ពីក្រុមប្រឆាំងនិងក្រុមសិទ្ធិមនុស្សថា គណបក្សប្រជាជនកម្ពុជាកំពុងរឹតបន្តឹងការក្ដោបក្ដាប់អំណាចរបស់ខ្លួនថែមទៀតលើកម្លាំងយោធា និងប៉ូលិសដែលពាក់ព័ន្ធនឹងនយោបាយ ស្រាប់ ឱ្យខំថែមទៀតដើម្បីការពារគណបក្សកាន់អំណាចជាងការពារប្រជាជន។

ឈ្មោះថ្មីមួយចំនួនក្នុងគណៈកម្មាធិការកណ្ដាលនេះជាអ្នកចេញមុខជាងគេក្នុងការបង្ក្រាបដោយរដ្ឋាភិបាលជួនកាលមានបង្ហូរឈាមផង លើបក្សប្រឆាំងនិងការតវ៉ារបស់កម្មករកាត់ដេរ បន្ទាប់ពីការបោះឆ្នោតជាតិឆ្នាំ២០១៣។

មហាសន្និបាតនេះ ដែលជាលើកដំបូងហើយរបស់គណបក្សប្រជាជនកម្ពុជា ចាប់តាំងពីជិតចាញ់ឆ្នោតរបស់ខ្លួនក្នុងការបោះឆ្នោតជាតិ គឺមានការពិភាក្សាគ្នាផុលផុសអំពីសេចក្ដីត្រូវការរបស់បក្សដើម្បីរៀនសូត្រពីបទពិសោធនិងកំណែទម្រង់។ លោក កាញារីទ្ធ មិនបានឱ្យដឹងច្រើន ថាកំណែទម្រង់ទាំងនោះជាអ្វីខ្លះនោះទេ។ លោកបានឱ្យដឹងអំពីការដំឡើងប្រាក់ខែនៅពេលខាងមុខសម្រាប់មន្ត្រីរាជការ និងកម្មករកាត់ដេរ និងបានអំពាវនាវឱ្យការិយាល័យរដ្ឋាភិបាលជាតិនិងមូលដ្ឋានជួលយុវជនច្រើនថែមទៀត និងប្រើហ្វេសប៊ុក និងធ្វីតធឺដើម្បីផ្សព្វផ្សាយការងាររបស់ខ្លួន។

លោកបានសន្មតថា ភាពខ្លាំងរបស់គណបក្សប្រឆាំងក្នុងការបោះឆ្នោតចុងក្រោយនេះគឺដោយសារការរួមបញ្ចូលគ្នារបស់បក្សប្រឆាំងធំៗកាលពីឆ្នាំ២០១២ ដើម្បីបង្កើតគណបក្សសង្គ្រោះជាតិ។

លោកបាននិយាយថា "អាសនៈរបស់យើងបានថយចុះដោយសារបក្សផ្សេងបានរួមកម្លាំងគ្នា ដូច្នេះវាមានអាសនៈច្រើន។ ដូច្នេះឥឡូវនេះ យើងពិនិត្យចំណុចខ្វះខាតដើម្បីពង្រឹង និងដាក់ចេញយុទ្ធសាស្ត្រដើម្បីបោះជំហានទៅមុខ"។ លោកបានបន្ថែមថា "ប្រសិនបើគណបក្សមិនរួបរួមគ្នាទេ ទ្រាំនឹងព្យុះមិនបានទេ"។

របាយការណ៍លេចធ្លាយមួយដែលគណបក្សប្រជាជនបានចែកឱ្យទៅសមាជិកនៅថ្ងៃដំបូងនៃមហាសន្និបាតមានភាពស្មោះត្រង់អំពីបញ្ហារបស់បក្សដោយចង្អុលបង្ហាញបញ្ហាទាំងនោះ រួមមានដូចជាអ្វីគ្រប់យ៉ាងចាប់ពីអំពើពុករលួយ និងញាតិបក្សនិយមរហូតដល់ការរំលោភអំណាចកង្វះជំនឿប្រជាជនលើប្រព័ន្ធយុត្តិធម៌និងអសមភាពសង្គមយ៉ាងខ្លាំង។ **តទៅទំព័រទី ១៩**

# Senior military and police officers received a promotion party

**MECH DARA | FEBRUARY 3, 2015**

Ruling Cambodian People's Party welcomed the new members of the Committee the General Assembly at the end of his party on Sunday, many of the new members in the Committee of the Central Party almost lost control of its decades of power in elections The national final.

This addition increased more than twice the committee members is central to 545 officials and senior military and police as well as the three sons of Prime Minister Hun Sen.

Speaks with reporters at the close of the convention Khieu Kanharith Minister boasted about adding 45 Committee Central and member of the "young" 70 under 50 years of age.

Of the 268 members of the committee of central leaders of the Congress on Friday 27, died from this committee convened the last meeting in 2013, he resigned from office and expelled from the party.

Kanharith, said that "we have added members because the members of the old age and died. We need to recruit young people because 50 percent of the country is less than 30 years old, so we chose a young, experienced ....We need enough qualified successor ".

He said the party did not amend the Standing Committee and chairman of the Central Committee, which is Senate President Chea Sim, who did not attend In this Congress, because the disease being treated in Vietnam, received his altar.

Kanharith unnamed one among the new members of the committee of the center.

But according to a list posted on the website of local Khmer said the list named three sons Prime Minister Hun Sen and a number of influential people in the military and police.

